# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ ២០១៧ របស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

## ១. ស្ថានភាពមន្ត្រីរាជការរបស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមានមន្ត្រីរាជការសរុបចំនួន ៣៤ នាក់ (ស្រី ១១ នាក់) ក្នុងនោះមានប្រធាននាយកដ្ឋាន ០១ នាក់ អនុប្រធាននាយកដ្ឋាន ០៤ នាក់ ប្រធានការិយាល័យ ០៤ នាក់ អនុប្រធានការិយាល័យ ១១ នាក់ និងមន្ត្រីក្រោមឱវាទ ១៤ នាក់ (០២ នាក់ ជាមន្ត្រីកម្មសិក្សា)។ ក្នុងចំនួនមន្ត្រីរាជការ ៣៤ នាក់ ក្នុងនោះ មានមន្ត្រីចំនួន ០៣ នាក់ បានទៅបំពេញការងារពេញម៉ោងនៅក្នុងគម្រោង និង ០២ នាក់ទៅបន្តការសិក្សា។

## ២.សកម្មភាព និងលទ្ធផលការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

### ២.១. កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទប្រើប្រាស់ថវិកាជាតិ

- រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសត្បាញក្រមាចំនួន ០២ វគ្គ ដែលមានសិក្ខាកាមចំនួន ៣០ នាក់ ស្រី ៣០ នាក់ នៅខេត្តកំពង់ចាម
- រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសត្បាញហូលចំនួន ០២ វគ្គ ដែលមានសិក្ខាកាមចំនួន ៣០ នាក់ ស្រី ៣០ នាក់ នៅខេត្តកំពង់ចាម
- រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតចង្ក្រានជីវៈឧស្ម័នផ្ទៃកមេជាងចំនួន ០១ វគ្គ ដែលមានសិក្ខាកាមចំនួន ០៥ នាក់ ប្រុស ០៥ នាក់ នៅខេត្តសៀមរាប
- រៀបចំវគ្គបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូចំនួន ០១ វគ្គ ដែលមានសិក្ខាកាមចំនួន ១៥ នាក់ ស្រី ០៦ នាក់ ប្រុស ០៩នាក់ នៅខេត្តត្បូងឃ្មុំ
- រៀបចំវគ្គបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូចំនួន ០៣ វគ្គ ដែលមានសិក្ខាកាមចំនួន ៣០ នាក់ ស្រី ១០ នាក់ ប្រុស ២០ នាក់ (១០ នាក់/វគ្គ) នៅខេត្តត្បូងឃ្មុំ
- រៀបចំវគ្គបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូចំនួន ០៣ វគ្គ ដែលមានសិក្ខាកាមចំនួន ៣០ នាក់ ស្រី ០៨ នាក់ ប្រុស ២២ នាក់ (១០ នាក់/វគ្គ) នៅខេត្តកំពង់ឆ្នាំង
- ចុះសិក្សាពីតម្រូវការអាជីវកម្មខ្នាតគ្រួសារ និងខ្នាតតូច ចំនួន ០១ ក្រុម ដែលមានសិក្ខាកាមចំនួន ៣០ គ្រួសារ ស្រី ២៥ នាក់ ប្រុស ០៥ នាក់ នៅខេត្តកំពត
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងចលនាភូមិថ្មី នៅខេត្តកំពង់ស្ពឺ
- ចុះសិក្សាពីតម្រូវការអាជីវកម្មខ្នាតគ្រួសារ និងខ្នាតតូច ចំនួន ០១ ក្រុម ដែលមានអ្នកចូលរួមចំនួន ៣០ គ្រួសារ ស្រី ២៥ នាក់ ប្រុស ០៥ នាក់ នៅខេត្តព្រះសីហនុ
- សិក្សាពីតម្រូវការអាជីវកម្មខ្នាតគ្រួសារ និងខ្នាតតូច ចំនួន ០១ ក្រុម ដែលមានអ្នកចូលរួមចំនួន ៣០ គ្រួសារ ស្រី ២៥ នាក់ ប្រុស ០៥ នាក់ នៅខេត្តពោធិ៍សាត់
- សិក្សាពីតម្រូវការអាជីវកម្មខ្នាតគ្រួសារ និងខ្នាតតូច ចំនួន ០១ ក្រុម ដែលមានអ្នកចូលរួមចំនួន ៣០ គ្រួសារ ស្រី ២៥ នាក់ ប្រុស ០៥ នាក់ នៅខេត្តបាត់ដំបង

- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងឥណទានជនបទ នៅខេត្តបាត់ដំបង
- ចុះសិក្ខាសាលាផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុប ១៨០ នាក់ ស្រី ៧៥ នាក់

**២.២. ការងារឥណទានជនបទ**

**២.២.១. ការងារឥណទានជនបទគាំទ្រដោយវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ**

- គិតត្រឹមថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១៧ គម្រោងឥណទានខ្នាតតូចដែលគាំទ្រថវិកាដោយកូរ៉េ បានផ្តល់ឥណទានសរុបចំនួន **៣៨៧ ៧៧៣ ៨០០ រៀល** (បីរយប៉ែតសិបប្រាំពីរលានប្រាំពីររយចិតសិបបីពាន់ប្រាំបីរយរៀល) ស្មើនឹង **៩៦ ៩៤៣ ,៤៥ ដុល្លារអាមេរិក** (កៅសិបប្រាំមួយពាន់ប្រាំបួនរយសែសិបបីដុល្លារនិងសែសិបប្រាំសេន)និងមានអ្នកខ្ចីសរុបចំនួន **១៣៧** នាក់ ក្នុងនោះខេត្តត្បូងឃ្មុំមានផលប័ត្រឥណទានចំនួន **២៥៦ ២៤១ ០០០ រៀល** (ពីររយហាសិបប្រាំមួយលានពីររយសែសិបមួយពាន់រយរៀល) សម្រាប់អតិថិជន **៨០** នាក់ និងខេត្តកំពង់ចាមមានផលប័ត្រឥណទានចំនួន **១៣១ ៥៣២ ៨០០ រៀល** (មួយរយសាមសិបមួយលានប្រាំរយសាមសិបពីរពាន់ប្រាំបីរយរៀល) សម្រាប់អតិថិជន **៥៧** នាក់។
- តំបន់ប្រតិបត្តិការរបស់គម្រោងមានចំនួន **១៨** ភូមិ រួមមាន÷
  - ខេត្តត្បូងឃ្មុំ÷ ភូមិ២ ភូមិ៣ ភូមិ៥ ក្នុងឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ភូមិត្របុស្ស ភូមិខ្លោង ភូមិត្រពាំងដុំ ភូមិអង្គរជ័យ ក្នុងឃុំស្រឡប់ ភូមិវិហារសំបួរ ឃុំរការពរប្រាំ ភូមិស្នោង ឃុំល្មៀង ស្រុកត្បូងឃ្មុំ ភូមិទួលសំបួរ ភូមិថ្មីសំណាង ភូមិទួលមានជ័យ ភូមិអ្នកតាទ្វារ ឃុំព្រះធាតុ ស្រុកអូរាំងឪ ភូមិព្រះអណ្តូង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក។
  - ខេត្តកំពង់ចាម÷ ភូមិតុងរ៉ុង ភូមិប្រសាទ ភូមិផ្ទះខ្ពស់ ភូមិដូង ក្នុងឃុំតុងរ៉ុង ស្រុកព្រៃឈរ។
- ដើមទុនបង្វិលទទួលពី KREI ដំបូងពេលចាប់ផ្តើមគម្រោង **៣៤៦ ០១៨ ៧៣០ រៀល** (បីរយសែសិបប្រាំមួយលានដប់ប្រាំបីពាន់ប្រាំពីររយសាមសិបរៀល) ស្មើនឹង **៨៦ ៥០៤,៦៨ ដុល្លារអាមេរិក** (ប៉ែតសិបប្រាំមួយពាន់ប្រាំរយបួនដុល្លារនិងហុកសិបប្រាំបីសេន)។
- ដើមទុនសរុបនៃគម្រោងឥណទាន (Total Asset) គិតត្រឹមថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១៧ មានចំនួន **៤៦៣ ៦៨៦ ៥១២ រៀល** (បួនរយហុកសិបបីលានប្រាំមួយរយប៉ែតសិបប្រាំមួយពាន់ប្រាំរយដប់ពីររៀល) ស្មើនឹង **១១៥ ៩២១,៦៣ ដុល្លារអាមេរិក** (មួយរយដប់ប្រាំពាន់ប្រាំបួនរយម្ភៃមួយដុល្លារនិងហុកសិបបីសេន) (អត្រាប្តូរប្រាក់ ៤០០០៛ ក្នុង ១ USD) កើនលើសដើមទុនដំបូងចំនួន **១១៧ ៦៦៧ ៧៨២ រៀល** (មួយរយដប់ប្រាំពីរលានប្រាំមួយរយហុកសិបប្រាំពីរពាន់ប្រាំពីររយប៉ែតសិបពីររៀល) ស្មើនឹង **២៩ ៤១៦,៩៥ ដុល្លារអាមេរិក** (ម្ភៃប្រាំបួនពាន់បួនរយដប់ប្រាំមួយដុល្លារនិងកៅសិបប្រាំសេន)។

- **តារាងតុល្យការខេត្តកំពង់ចាម**

ក. ទ្រព្យសកម្ម (Assets)

- ចំនួនប្រាក់នៅក្នុងបេឡា.........................................: ៣ ០៦៨ ៣០០ រៀល
- ចំនួនប្រាក់ផ្ញើនៅធនាគារ........................................: ៧ ០៤៤ ២៣០ រៀល
- ចំនួនប្រាក់ឥណទានកំពុងស្ថិតនៅក្នុងដៃអតិថិជន............: ១៣១ ៥៣២ ៨០០ រៀល
- តម្លៃនៅសល់នៃអចលនទ្រព្យ(ដករំលស់បង្គររួច)............: ៥ ៥០០ ៨៨០ រៀល
- **សរុបទ្រព្យសកម្ម............................................... : ១៤៧ ១៤៦ ២១០ រៀល**

ខ. ទ្រព្យមូលធន (Liabilities and Capital)

- ដើមទុនទទួលបានពីប្រទេសកូរ៉េ (ឆ្នាំ២០១៧)................: ១៩៧ ៨២២ ១៧០ រៀល
- ចំណូលបង្គរ.........................................................: (៤៨ ៤៧៥ ១២០) រៀល
- ចំណេញពិតក្នុងខែ..................................................: (២ ២០០ ៨៤០) រៀល
- **សរុបទ្រព្យមូលធន............................................. : ១៤៧ ១៤៦ ២១០ រៀល**

### ▪ តារាងតុល្យការខេត្តត្បូងឃ្មុំ

ក. ទ្រព្យសកម្ម (Assets)

- ចំនួនប្រាក់នៅក្នុងបេឡា..........................................: ២ ៥៥៣ ១១២ រៀល
- ចំនួនប្រាក់ផ្ញើនៅធនាគារ........................................: ៦២ ៩៩៤ ៨០០ រៀល
- ចំនួនប្រាក់ឥណទានកំពុងស្ថិតនៅក្នុងដៃអតិថិជន............: ២៥៦ ២៤១ ០០០ រៀល
- ចំនួនប្រាក់បម្រុងនឹងបាត់បង់ ....................................: (៥ ២៤៨ ៦១០) រៀល
- **សរុបទ្រព្យសកម្ម............................................... : ៣១៦ ៥៤០ ៣០២ រៀល**

ខ. ទ្រព្យមូលធន (Liabilities and Capital)

- ដើមទុន (បានទទួលពីកំពង់ចាមទាំងពីរលើក រួមអចលនៈទ្រព្យ) : ៣៧៥ ១៩៦ ៥៦៦ រៀល
- ប្រាក់ខាតបង់ (បង្គរ) .............................................: (២១ ៣៦៤ ៧៨១,៥២) រៀល
- ប្រាក់រកបាន (បង្គរ) ...............................................: ( ៣ ៩៨៨ ៦៨២,៤៨) រៀល
- ដកទិញរថយន្ត ......................................................: (៣៣ ៣០២ ៨០០) រៀល
- **សរុបទ្រព្យមូលធន............................................... : ៣១៦ ៥៤០ ៣០២ រៀល**

### ២.២.២. លទ្ធផលការងារឥណទានជនបទនៅតាមបណ្ដារាជធានី ខេត្ត

គិតត្រឹមថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៧ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្ដល់ឥណទានសរុបចំនួន **៥ ២២៤ ៤៦៣ ០០០ រៀល** (ប្រាំពាន់ពីររយម្ភៃបួនលានបួនរយហុកសិបបីពាន់រៀល) ស្មើនឹង **១ ៣០៦ ១១៥,៧៥ ដុល្លារអាមេរិក** (មួយលានបីរយប្រាំមួយពាន់មួយរយដប់

ប្រាំដុល្លារនិងចិតសិបប្រាំសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន **៦ ០១៥** នាក់នៅភូមិគោលដៅចំនួន **២១៩** ភូមិ **៧៩** ឃុំ **៣៤** ស្រុក ក្នុងខេត្តគោលដៅចំនួន **១៥** ដូចខាងក្រោម÷

| ល.រ | ខេត្ត | ឥណទានកំពុងប្រើប្រាស់ដោយអតិថិជន ($) | ចំនួនអ្នកខ្ចី (នាក់) | ស្ត្រី (នាក់) | ចំនួនភូមិ | ចំនួនឃុំ | ចំនួនស្រុក |
|---|---|---|---|---|---|---|---|
| **I. ប្រតិបត្តិការឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | | |
| ១ | កំពង់ចាម | ៣៤៥,៥០០.០០ | ១ ១០៦ | ៩៨៦ | ៤២ | ១៤ | ៥ |
| ២ | ត្បូងឃ្មុំ | ១៥៦,២០៤.៤០ | ២០៥ | ១៥៦ | ២៣ | ៧ | ៤ |
| ៣ | បាត់ដំបង | ៥៥,៧០៨.១៣ | ២១៧ | ១៨៦ | ១២ | ៧ | ៤ |
| ៤ | ព្រះសីហនុ | ១,៤៧៥.០០ | ២៦ | ២២ | ១ | ១ | ១ |
| ៥ | តាកែវ | ៣៩,៦៣០.៨៨ | ១៨៨ | ១៣៧ | ១៤ | ៧ | ២ |
| ៦ | កំពង់ស្ពឺ | ១,៨១៨.៧៥ | ២១ | ១៩ | ១ | ១ | ១ |
| ៧ | កំពង់ធំ | ២,៨៤២.៥០ | ២៧ | ២៦ | ២ | ១ | ១ |
| ៨ | ស្ទឹងត្រែង | ៤៥១.៦០ | ៣ | ៣ | ១ | ១ | ១ |
| ៩ | កំពង់ឆ្នាំង | ៤,២៨៧.៥០ | ៣៦ | ៣៤ | ២ | ១ | ១ |
| សរុប (I) | | ៦០៧,៩១៨.៧៥ | ១ ៨២៩ | ១ ៥៦៩ | ៩៨ | ៤០ | ២០ |
| **II. ការងារឥណទានសហប្រតិបត្តិការជាមួយអង្គការដៃគូ** | | | | | | | |
| ១ | កំពត | ៨៥,០២៥.០០ | ៣១២ | ៣០៦ | ១៤ | ៨ | ១ |
| ២ | ពោធិ៍សាត់ | ២៤៧,៨៦៥.០០ | ១ ០៨៣ | ១ ០៣៣ | ៣៨ | ១៣ | ៥ |
| ៣ | សៀមរាប | ៣៦,៨០០.០០ | ១៦៩ | ១៥០ | ៧ | ៦ | ៣ |
| ៤ | កោះកុង | ៩៥,០៥០.០០ | ៤៨៥ | ៣៩៣ | ១១ | ៥ | ២ |
| ៥ | បន្ទាយមានជ័យ | ៨២,២៨០.០០ | ៣៥៨ | ២៨៤ | ៤ | ១ | ១ |
| សរុប (II) | | ៥៤៧,០២០.០០ | ២ ៤០៧ | ២ ១៦៦ | ៧៤ | ៣៣ | ១២ |
| **III. ការងារឥណទានសហគមន៍** | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ស្វាយរៀង | ១២៦,៨៧៧.០០ | ១ ២៦៦ | ៧៧០ | ៤៥ | ៥ | ១ |
| ២ | កំពង់ចាម (ស្រុកបាធាយ) | ២៤,៣០០.០០ | ៥១៣ | ៥១៣ | ២ | ១ | ១ |
| សរុប (III) | | ១៥១,១៧៧.០០ | ១ ៧៧៩ | ១ ២៨៣ | ៤៧ | ៦ | ២ |
| **សរុបរួម (I,II,III)** | | **១,៣០៦,១១៥.៧៥** | **៦ ០១៥** | **៥ ០១៨** | **២១៩** | **៧៩** | **៣៤** |

**២.៣. ការងារធនាគារស្រូវ**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន **១៥ ៦០០ គ.ក្រ** គិតជាទឹកប្រាក់ស្មើនឹង **២ ៧៣០** ដុល្លារអាមេរិក(ពីរពាន់ប្រាំពីររយសាមសិបដុល្លារអាមេរិក) **ស្ថិតនៅក្នុងជង្រុក។**

## ៣. សកម្មភាពប្រជុំសិក្ខាសាលានិងការងារផ្សេងៗ

- បានចូលរួមប្រជុំពិនិត្យឡើងវិញរបាយការណ៍វឌ្ឍនៈភាពនៃការអនុវត្តសកម្មភាពត្រីមាសទី៤ ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារីម** អនុរដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមស្តីពីការរៀបចំពិធីអបអរសាទរខួបលើកទី៣៨ ទិវា ៧មករា ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី៣ នៃទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមប្រជុំប្រចាំសប្តាហ៍ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមប្រជុំស្តីពីការរៀបចំរបាយការណ៍ និងតារាងផែនការសកម្មភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទសម្រាប់សហគមន៍សង្គម-វប្បធម៌អាស៊ាន ការលើកគម្រោងស្នើសុំកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំស្តីពី ការបូកសរុបលទ្ធផលស្នើសុំគម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងការលើកគម្រោងស្នើសុំជំនួយក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំស្តីពី ការរៀបចំគម្រោងសម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងរចនាសម្ព័ន្ធរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងាររៀបចំចងក្រងការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៦ និងទិសដៅឆ្នាំ ២០១៧ ក្រោមអធិបតីភាពឯកឧត្តម **ហួត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- បានចូលរួមកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការសម្របសម្រួល និងរៀបចំវេទិកាចិន-អាស៊ានលើកទី១១ ស្តីពីការអភិវឌ្ឍសង្គម និងកាត់បន្ថយភាពក្រីក្រ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ ខួបលើកទី១០៦ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ នៅភោជនីយដ្ឋានទន្លេបាសាក់២
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **ហួត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការរៀបចំសន្និបាត កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកម្មវិធីកាត់ឫសសីមា និងសម្ពោធសមិទ្ធផលនានាក្នុងវត្តតុណ្ឌបព្វតារាម (ហៅវត្តភ្នំចំពុះ) ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៧ នៅខេត្តកំពង់ឆ្នាំង

- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការរៀបចំសន្និបាត កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីដំណើរការរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌឆ្នាំ២០១៧ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការរៀបចំសន្និបាត កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមប្រជុំស្តីពីដំណើរការរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌឆ្នាំ២០១៧ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកម្មពិធីសូត្រមន្តចម្រើនព្រះបរិត្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃ១១កើត ខែចេត្រ អដ្ឋស័ក ព.ស ២៥៦០ គ.ស ២០១៧ ត្រូវនឹងថ្ងៃសុក្រ ទី៧ ខែមេសា ឆ្នាំ២០១៧ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមអមដំណើរ**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ក្នុងកម្មវិធីសួរសុខទុក្ខកងទ័ព កងពលតូចថ្មើរជើងលេខ ៥២ និងពិធីប្រកាសចូលកាន់តំណែងប្រធានមន្ទីរ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៧
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលចលនាភូមិថ្មី កាលពីថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី១ ទីស្តីការក្រសួង
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលចលនាភូមិថ្មី កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី១ ទីស្តីការក្រសួង
- បានចូលរួមកិច្ចប្រជុំពិភាក្សាកែសម្រួលលើឯកសារ Country Programme Framework (CPF) ជាមួយជំនាញការ IAEA កាលពីថ្ងៃទី០៨-១២ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គនាយកដ្ឋានថាមពល អាគារ១៣-១៤ ផ្លូវសហព័ន្ធរុស្ស៊ី ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានចូលរួមក្នុងពិធីបុណ្យវិសាខបូជា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល

- បានចូលរួមសិក្ខាសាលាស្តីពី Poverty Reduction through Rural Transportation and Water Resources for Developing Countries in 2017 ទីក្រុងប៉េកាំង សាធារណៈរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១០-២៤ ខែឧសភា ឆ្នាំ២០១៧
- បានចូលរួមសិក្ខាសាលាអន្តរជាតិស្តីពី Sharing Experiences in Poverty Reduction in Belt and Road Countries នៅសាធារណៈរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី ១៨-១៩ ខែឧសភា ឆ្នាំ ២០១៧
- បានចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីការបណ្តុះបណ្តាលដែលទទួលបានពីក្រៅប្រទេស កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- បានចូលរួមសិក្ខាសាលាស្តីពី តម្រូវការវគ្គបណ្តុះបណ្តាលតាមអង្គភាពក្រោមឱវាទក្រសួង កាលពីថ្ងៃទី ២៣-២៤ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- បានចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាជំនាញប្រើប្រាស់កម្មវិធី Advanced Microsoft Excel កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី១ ទីស្តីការក្រសួង
- បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួល និងរៀបចំវេទិកា អាស៊ាន-ចិន លើកទី ១១ ស្តីពីការអភិវឌ្ឍន៍សង្គម និងកាត់បន្ថយភាពក្រីក្រ ការពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី១ ទីស្តីការក្រសួង
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ ស្តីពីការដាក់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងការបណ្តុះបណ្តាលដល់មន្ត្រីជំនាញក្នុងការវិភាគចំណាយ និងផលចំណេញ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី១ ទីស្តីការក្រសួង
- បានចូលរួមសិក្ខាសាលាស្តីពី The Seminar on Anti-Poverty Issues in Development Countries from June 9-29,2017 in Beijing, China
- បានចូលរួមសិក្ខាសាលាលើកទី ស្តីពីកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងត្រីភាគីដើម្បីជំរុញការអភិវឌ្ឍ តាមរយៈវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងពីធីសម្ពោធកម្មវិធីកសាងសមត្ថភាពរបស់សាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យការងារប្រចាំថ្ងៃរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- បានចូលរួមប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៩ អាណត្តិទី៤ កាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៧ នៅសាលសន្និសីទបន្ទប់លេខ១ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានចូលរួមកិច្ចប្រជុំកែសម្រួលលើតារាងពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រង កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង

**៤.ទិសដៅអនុវត្តបន្ត**

- បន្តពង្រីកគម្រោងឥណទានទៅតាមបណ្តាខេត្តផ្សេងៗ
- បន្តរៀបចំចងក្រងឯកសារគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងដំណើរការសហគមន៍សន្សំប្រាក់
- បន្តចុះពិនិត្យ និងវាយតម្លៃគម្រោងឥណទានជនបទតាមបណ្តារាជធានីខេត្តតាមផែនការគ្រោងទុក
- ជំរុញការផ្តល់ឥណទាន និងប្រមូលត្រឡប់មកវិញឲ្យបានក្នុងកម្រិតអតិបរមាសម្រាប់ខេត្តគោលដៅដែលគ្រប់គ្រងផ្ទាល់ និងបង្កើនកិច្ចសហការជាមួយអង្គការដៃគូ
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារនិងខ្នាតតូច
- ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- បន្តរៀបចំឯកសារគោលការណ៍នីតិវិធីនិងឯកសារគតិយុត្តិតាមវិស័យដូចជា ឥណទានជនបទសហគ្រាសខ្នាតតូច និងរកទីផ្សារសម្រាប់ផលិតផលជនបទ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍នានា
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការតាមរយៈការបើកវគ្គនៅនឹងកន្លែង ការបញ្ជូនមន្ត្រីឲ្យទៅចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលនានា ការផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីនាយកដ្ឋានជាមួយនឹងមន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត និងស្ថាប័នផ្សេងៗ និងលើកទឹកចិត្តឲ្យមន្ត្រីសិក្សាស្រាវជ្រាវពីចំណេះដឹងថ្មីៗបន្ថែមដោយខ្លួនឯង
- ពង្រឹងការតាមដាន និងវាយតម្លៃដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងារ។